គណបក្សជាតិខ្មែរ

**KHMER NATION PARTY**
**PARTI DE LA NATION KHMÈRE**

PRESS FILE

JASON

Phnom Penh, 20 October 1996

# PIN PISITH MUST BE RELEASED IMMEDIATELY

The Khmer Nation Party (KNP) deeply regrets the decision of the Phnom Penh Municipal Court to continue to detain Pin Pisith in the notorious T3 prison reserved for criminals.

A chauffeur and a security guard at KNP, Pin Pisith was arrested and a KNP car confiscated by Phnom Penh municipal police forces on 16 October 1996 at around 8.30 a.m. during the peaceful demonstration staged by KNP in support of democracy and human rights in Burma and Cambodia. Up until now, neither Pin Pisith nor the car have been released by the authorities. Moreover, the Phnom Penh Municipal Court has ordered to send Pisith to T3 jail where his hair were cut short, he had to wear prisoners uniforms and he was handcuffed when brought to Court for interrogation, like a convicted criminal.

It is because the government armed forces tried to prevent KNP leaders and members from walking through Street 214 (in front of KNP headquarters) that an incident occurred in which a policeman got his leg scratched. If the authorities had respected the Constitution and the right of citizens to express their opinion and to demonstrate peacefully, such an incident would not have occurred. It did occur only because of the resulting confrontation between the armed forces and KNP demonstrators who wanted to leave their party headquarters long before the arrival in Phnom Penh of the Burmese military delegation. The arrest of Pin Pisith after a minor and involuntary clash is unfair, it is an abuse of human rights which the authorities should be ashamed of. The fact that the government makes such a big deal out of a small incident is a political matter related to a political demonstration organized by a political party and banned by the government for political reasons. So, if any problem arises, it is the government and the political party leadership which should be held responsible and not Pin Pisith, a KNP member who merely obeyed his party leaders' instructions. As for myself, in my capacity as KNP president, I am prepared to answer questions of any court which would be competent for a political matter of this kind.

On the same day, the armed forces arrested a KNP staff member named Han Many, beat and kicked him until he fainted. Up until today, he has to undergo treatment at Preah Norodom Sihanouk Hospital (former Russian Hospital). The barbarian aggression by the soldiers has been videotaped by foreign journalists and the victim has filed a complaint with the tribunal. Yet KNP does not demand the arrest and the imprisonment of anybody. KNP considers that the way Pin Pisith has been treated is an act of open intimidation vis-à-vis democratic opponents aimed at undermining their determination.

KNP demands that the authorities release Pin Pisith immediately.

[signed]

SAM RAINSY
President

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ១០ ផ្លូវ សម្តេចប៉ាន់ (២១៤) សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Headquarters : House # 10, Street 214, Phnom Penh, Kingdom of Cambodia**
**Siège : Maison N° 10, Rue 214, Phnom Penh, Royaume du Cambodge**
**Tel / Fax : 23 - 723 451**

## គណបក្សជាតិខ្មែរ
**KHMER NATION PARTY**
**PARTI DE LA NATION KHMÈRE**

# ត្រូវដោះលែងលោក ពិន ពិសិដ្ឋ ជាបន្ទាន់

គណបក្សជាតិខ្មែរ មានការសោកស្ដាយយ៉ាងខ្លាំង ចំពោះទង្វើរបស់តុលាការក្រុងភ្នំពេញ ដែលនៅតែបន្តឃុំខ្លួនលោក ពិន ពិសិដ្ឋ ក្នុងពន្ធនាគារឧក្រិដ្ឋ តេបី ( T3 ) ។

លោក ពិន ពិសិដ្ឋ ដែលជាអ្នកបើកបររថយន្តគណបក្សជាតិខ្មែរ និង ជាភ្នាក់ងារសន្តិសុខរបស់គណបក្សជាតិខ្មែរផងដែរ ត្រូវបានអាជ្ញាធរប្រដាប់អាវុធរបស់រដ្ឋាភិបាលភ្នំពេញ ឃាត់ខ្លួនជាមួយរថយន្តមួយគ្រឿងកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៦ វេលាម៉ោង៨ និង ៣០នាទីព្រឹក នៅក្នុងឱកាសបាតុកម្មដោយសន្តិវិធី គាំទ្រលទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្សនៅភូមា និង នៅកម្ពុជា ដែលរៀបចំឡើងដោយគណបក្សជាតិខ្មែរ ។ រហូតមកដល់ថ្ងៃនេះ លោក ពិន ពិសិដ្ឋ និង រថយន្តមិនទាន់ត្រូវបានអាជ្ញាធរ ដោះលែងឱ្យមានសេរីភាព និង ប្រគល់ឱ្យគណបក្សមកវិញ នៅឡើយទេ ។ មិនតែប៉ុណ្ណោះ តុលាការក្រុងភ្នំពេញបានចេញដីកាឃុំខ្លួនលោក ពិន ពិសិដ្ឋ នៅក្នុងពន្ធនាគារឧក្រិដ្ឋ តេបី ( T3 ) ដោយបង្ខំឱ្យគាត់សក់យ៉ាងខ្លី ស្លៀកពាក់សំលៀកបំពាក់អ្នកទោស និង ដាក់ខ្នោះដៃក្នុងពេលនាំខ្លួនមកតុលាការ ដើម្បីសួរចំលើយប្រៀបដូចជាជនឧក្រិដ្ឋ ។

គ្រោះថ្នាក់ដោយចៃដន្យដ៏ស្រាល ដែលបណ្ដាលឱ្យប៉ូលីសម្នាក់រលាត់ស្បែកបន្តិចនៅលើជើង កើតឡើងដោយសារតែអាជ្ញាធរប្រដាប់អាវុធបានរារាំងមិនឱ្យថ្នាក់ដឹកនាំ និង សមាជិកគណបក្សជាតិខ្មែរចាកចេញពីទីស្នាក់ការកណ្ដាលរបស់ខ្លួន ដើម្បីធ្វើដំណើរតាមផ្លូវលេខ ២១៤ ។ បើរដ្ឋអំណាចចេះគោរពរដ្ឋធម្មនុញ្ញ និង ចេះគោរពសិទ្ធិប្រជាពលរដ្ឋ ក្នុងការសំដែងមតិ និង ធ្វើបាតុកម្មដោយសន្តិវិធីនោះ ច្បាស់ជាមិនមានឧប្បត្តិហេតុបែបនេះ កើតមានឡើយ ។ ឧប្បត្តិហេតុនេះ បានកើតឡើងដោយសារការប្រឈមមុខរវាងអាជ្ញាធរប្រដាប់អាវុធ និង គណៈប្រតិភូគណបក្សជាតិខ្មែរ ដែលព្យាយាមធ្វើដំណើរចេញពីទីស្នាក់ការគណបក្ស មុនការមកដល់នៃមេដឹកនាំយោធាភូមា ។ ការចាប់ឃុំខ្លួនលោក ពិន ពិសិដ្ឋ ដោយសារការប៉ះទង្គិចគ្នាបន្តិចបន្តួចដោយអចេតនានេះ គឺជាអំពើអយុត្តិធម៌ និង រំលោភសិទ្ធិមនុស្សគួរឱ្យអៀនខ្មាស់ពីសំណាក់រដ្ឋអំណាច ។ រឿងរ៉ាវបន្តិចបន្តួច ដែលរដ្ឋាភិបាលចង់យកមកធ្វើជាធំនេះ គឺជារឿងនយោបាយ ទាក់ទងនឹងបាតុកម្មនយោបាយមួយ រៀបចំឡើងដោយគណបក្សនយោបាយមួយ ដែលរដ្ឋាភិបាលចង់ហាមឃាត់ដោយមូលហេតុនយោបាយ ។ ដូច្នេះ បើមានវិវាទអ្វីមួយកើតឡើង គឺរដ្ឋាភិបាល និង មេដឹកនាំគណបក្សនយោបាយទេ ដែលជាអ្នកទទួលខុសត្រូវ ហើយមិនត្រូវធ្វើទុក្ខទោសទៅលើលោក ពិន ពិសិដ្ឋ ដែលគ្រាន់តែជាសមាជិកគណបក្សជាតិខ្មែរម្នាក់ ដែលធ្វើតែតាមការណែនាំរបស់មេដឹកនាំគណបក្សរបស់ខ្លួនតែប៉ុណ្ណោះ ។ ចំណែករូបខ្ញុំ ក្នុងឋានៈខ្ញុំជាប្រធានគណបក្សជាតិខ្មែរ ខ្ញុំត្រៀមខ្លួនជានិច្ច ដើម្បីទៅឆ្លើយតបនឹងសំនួររបស់តុលាការ ដែលមានតួនាទីដោះស្រាយវិវាទនយោបាយបែបនេះ ។



ទីស្នាក់ការកណ្ដាល : ផ្ទះលេខ ១០ ផ្លូវ សម្ដេចប៉ាន់ (២១៤) សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 10, Street 214, Phnom Penh, Kingdom of Cambodia
Siège : Maison N° 10, Rue 214, Phnom Penh, Royaume du Cambodge
Tel / Fax : 23 - 723 451

សូមជំរាបមតិសាធារណៈថា នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៦ ដដែលនោះ កងប្រដាប់អាវុធរដ្ឋាភិបាល បានចាប់បុគ្គលិកគណបក្សជាតិខ្មែរម្នាក់ ឈ្មោះ ហាន ម៉ានី យកទៅវាយដំទាត់ធាក់ រហូតដល់សន្លប់ ហើយជនរងគ្រោះត្រូវនៅសំរាកព្យាបាលខ្លួន នៅមន្ទីរពេទ្យព្រះបាទនរោត្តមសីហនុ ( អតីតពេទ្យរុស្ស៊ី ) មកទល់នឹងថ្ងៃនេះ ។ អំពើព្រៃផ្សៃនេះ បានត្រូវអ្នកសារពត៌មានអន្តរជាតិថតរឹយអូទុកជាភស្តុតាងរួចហើយ ហើយសាមីខ្លួនក៏បានដាក់ពាក្យបណ្តឹងទៅតុលាការ ។ តែគណបក្សជាតិខ្មែរ មិនទាមទារឱ្យចាប់នរណាយកទៅដាក់គុកនោះឡើយ ។ គណបក្សជាតិខ្មែរមើលឃើញថា ការប្រព្រឹត្តរបស់អាជ្ញាធរមានសមត្ថកិច្ចទៅលើរូបលោក ពិន ពិសិដ្ឋ បែបនេះ គឺជាការគំរាមកំហែងជាចំហដល់គណបក្សជាតិខ្មែរ ក្នុងគោលបំណងបំបាក់ស្មារតីអ្នកប្រឆាំងបែបប្រជាធិបតេយ្យ ។

គណបក្សជាតិខ្មែរ ទាមទារឱ្យរដ្ឋអំណាចដោះលែងលោក ពិន ពិសិដ្ឋ ជាបន្ទាន់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៦

ប្រធានគណបក្ស

Sam Rainsy

សម រង្ស៊ី